## ជូនចំពោះកម្មសិក្សាការីហ្វឹកហ្វឺនជំនាញទាំងអស់

# សូមប្រើការឈប់សម្រាកប្រចាំឆ្នាំដែលមានប្រាក់ឈ្នួល!

### អ្វីទៅថ្ងៃឈប់សម្រាកប្រចាំឆ្នាំដែលមានប្រាក់ឈ្នួល?

- ថ្ងៃឈប់សម្រាកប្រចាំឆ្នាំដែលមានប្រាក់ឈ្នួលគឺជាការឈប់សម្រាកដោយមានបង់ប្រាក់ឈ្នួល។ គឺជាសិទ្ធិដែលផ្តល់ឱ្យកម្មករដូចមានបានចែងក្នុងច្បាប់។



- ក្រោយពីចាប់ផ្តើមធ្វើការបាន៦ខែឡើង ហើយប្រសិនបើទៅធ្វើការបាន៨០%ឡើងទៅ គឺអាចប្រើថ្ងៃសម្រាកប្រចាំឆ្នាំដែលមានប្រាក់ឈ្នួលបាន។ កម្មសិក្សាការីហ្វឹកហ្វឺនក៏ដូចគ្នានឹងជនជាតិជប៉ុនដែរ។

### តើទទួលបានថ្ងៃឈប់សម្រាកប្រចាំឆ្នាំដែលមានប្រាក់ឈ្នួលប៉ុន្មានថ្ងៃ?

- ការឈប់សម្រាកប្រចាំឆ្នាំដែលមានប្រាក់ឈ្នួល ត្រូវបានផ្តល់ឱ្យស្របតាមចំនួនឆ្នាំដែលបានធ្វើការ។

| ចំនួនឆ្នាំដែលបានធ្វើការ | ៦ខែ | ១ឆ្នាំ៦ខែ | ២ឆ្នាំ៦ខែ | ៣ឆ្នាំ៦ខែ | ៤ឆ្នាំ៦ខែ |
|---|---|---|---|---|---|
| ចំនួនថ្ងៃនៃការឈប់សម្រាក | ១០ថ្ងៃ | ១១ថ្ងៃ | ១២ថ្ងៃ | ១៤ថ្ងៃ | ១៦ថ្ងៃ |

## តើត្រូវប្រើការឈប់សម្រាកប្រចាំឆ្នាំដែលមានប្រាក់ឈ្នួលយ៉ាងដូចម្ដេច?

- អ្នកត្រូវជម្រាបទុកជាមុននូវថ្ងៃដែលអ្នកប្រើជាការឈប់សម្រាកប្រចាំឆ្នាំដែលមានប្រាក់ឈ្នួល។
- សូមជម្រាបទៅកន្លែងហ្វឹកហ្វឺនជំនាញ(ក្រុមហ៊ុន)ឱ្យបានឆាប់រហ័ស។

## តើប្រាក់ឈ្នួលនៅថ្ងៃដែលបានប្រើការឈប់សម្រាកប្រចាំឆ្នាំដែលមានប្រាក់ឈ្នួលគិតយ៉ាងដូចម្ដេចដែរ?

- មិនត្រូវបានកាត់បន្ថយប្រាក់ឈ្នួលទេ។

ប្រាក់ឈ្នួលត្រូវបានទូទាត់ឱ្យតាមកិច្ចសន្យា។

## តើគួរធ្វើដូចម្ដេចក្នុងករណីនេះ?

- ត្រូវបានបដិសេធពីកន្លែងហ្វឹកហ្វឺនជំនាញមិនឱ្យឈប់សម្រាកប្រចាំឆ្នាំដែលមានប្រាក់ឈ្នួល ត្រូវបានកាត់ប្រាក់ឈ្នួល ដោយសារប្រើការឈប់សម្រាកប្រចាំឆ្នាំដែលមានប្រាក់ឈ្នួល បានទទួលរងភាពអយុត្តិធម៌ពីក្រុមហ៊ុន

→អ្នកអាចពិគ្រោះយោបល់និងធ្វើការរាយការណ៍ជាភាសាកំណើតរបស់អ្នក។

សម្រាប់ព័ត៌មានលម្អិតសូមពិនិត្យមើលសៀវភៅសម្រាប់កម្មសិក្សាការីហ្វឹកហ្វឺនជំនាញ។



សូមប្រើការឈប់សម្រាកដែលមានប្រាក់ឈ្នួល

ដោយសម្រាកទាំងចិត្តទាំងកាយ ដើម្បីឱ្យមានកំលាំងមាំមួនក្នុងការហ្វឹកហ្វឺន។

ខែឧសភា ឆ្នាំរ៉េយវ៉ាក់៣